មជ្ឈមណ្ឌលឯកសារកម្ពុជា

# សវនាការបន្តស្តាប់សក្ខីកម្មរបស់លោក ស្ទីវ ហេដឺរ
# ដោយដកស្រង់ពត៍មានពីសៀវភៅ និងឯកសារមួយចំនួន

ដោយ សាយមិន ក្រូស័រ

ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣

*កែសម្រួលដោយ គីមស្រួយ សុខវិសាល*

នៅថ្ងៃព្រហស្បត្តិ៍ ទី១១ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តកិច្ចដំណើរការស្តាប់សក្ខីកម្មរបស់លោក ស្ទីវ ហេដឺរ ។ សវនាការនេះបានប្រព្រឹត្តទៅដោយមានការចូលរួមពីប្រជាពលរដ្ឋចំនួន ៣០០នាក់ ដែលអញ្ជើញមកពីខេត្តតាកែវ និងនិសិត្សច្បាប់ចំនួន ៧០នាក់ ចូលរួមស្តាប់នៅក្នុងសាលសាធារណៈរបស់តុលាការ ។ ភាគីដែលពាក់ព័ន្ធទាំងអស់សុទ្ធតែមានវត្តមាន លើកលែងតែជនជាប់ចោទ នួន ជា ដែលបានតាមដានសវនាការពីបន្ទប់ឃុំខ្លួនបណ្តោះអាសន្ន ដោយសារតែបញ្ហាសុខភាព ។

## សហព្រះរាជអជ្ញាបន្តសាកសួរ លោក ហេដឺរ

សហព្រះរាជអជ្ញា វេយន័រ ចាប់ផ្តើមដោយស្នើរឲ្យលោក ហេដឺ បញ្ជាក់អំពីសក្ខីកម្មរបស់លោកកាល ពីថ្ងៃមុនដែលលោកបានឮពាក្យស្លោក «ចម្រាញ់ប្រជាជនចេញពីពួកខ្មាំង» កាលពីមុន និងពេលដែលលោកស្តាប់ឮតាមវិទ្យុ ។ សហព្រះរាជអជ្ញាបានចោទសួរសាក្សីអំពីបរិបទដែលពាក្យស្លោកនេះត្រូវបានផ្សព្វផ្សាយតាមវិទ្យុ ។ លោក ហេដឺរ បានជម្រាបជូនតុលាការថាខ្មែរក្រហមប្រើពាក្យស្លោកនេះ នៅពេលដែលមានការប្រទាញប្រទង់គ្នាក្នុងការគ្រប់គ្រងប្រជាជន ។ ពាក្យស្លោកនេះសំដៅទៅលើការជម្លៀសប្រជាជនទៅកាន់តំបន់រំដោះ ។ ខ្មែរក្រហមប្រើប្រាស់ពាក្យស្លោកនេះសម្រាប់បម្រើឲ្យការឃោសនារបស់ខ្លួន ហើយស្តាប់ទៅហាក់ដូចជាខ្មែរក្រហមស្នើរសុំឲ្យប្រជាជនចាកចេញទៅតំបន់រំដោះ ដោយមិនមានការបង្ខំនោះឡើយ ។ ប៉ុន្តែតាមរយៈបទសម្ភាសន៍ លោក ហេដឺរ បានបញ្ជាក់ថា ពាក្យស្លោកនេះទាក់ទងជាមួយនឹងការជម្លៀសដោយបង្ខំ ។

សហព្រះរាជអជ្ញាបានបន្តចោទសួរ លោក ហេដឺរ អំពីការជម្លៀសប្រជាជនចេញពីខេត្តកំពង់ចាមថាតើប្រជាជនបានជម្លៀសដោយមានការបង្ខិតបង្ខំ ឬដោយស្ម័គ្រចិត្ត ។ លោក ហេដឺរ ឆ្លើយតបថា គាត់បានទៅដល់កន្លែងកើតហេតុនោះ ។ ប្រជាជនដែលគាត់សម្ភាសន៍បានប្រាប់ថា គាត់បានឃើញប្រជាជនមួយចំនួនចាកចេញពីភូមិដោយសារការបង្ខំ ខណៈពេលដែលប្រជាជនមួយចំនួន

ចាកចេញ ដោយស្មាក់ស្មើរ ប៉ុន្តែមិនមែនដោយសារការបង្ខំនោះទេ ។ លោក ហេដឌ័ បានប្រាប់អង្គជំនុំជម្រះថា ជាក់ស្តែងការជម្លៀស គឺធ្វើឡើងដោយបង្ខំ ។

នៅពេលពិភាក្សាអំពីហេតុការណ៍ដែលកើតឡើងនៅខត្តុងវិញ សាក្សីមិនបានដឹងច្បាស់ពីហេតុការណ៍នោះទេ ហើយក៏ពុំចាំថាតើការជម្លៀសនោះធ្វើឡើងដោយបង្ខំឬដោយស្ម័គ្រចិត្តនោះដែរ ។ គាត់អាចស្រមៃ ឃើញពីទិដ្ឋភាពយ៉ាងស្ងាត់ជ្រងំនៅខត្តុង ដោយមានប្រជាជនតែ៨-១០នាក់ប៉ុណ្ណោះ ដែលខ្មែរក្រហម មិនបានជម្លៀសចេញ ។ សាក្សីនៅចាំទៀតថា នៅពេលដែលទៅដល់វត្តមួយ គាត់បានឃើញសាកសពជូនជីដេកស្តូកស្តឹងនៅលើដី ហើយក៏ពុំមានអ្នកណាម្នាក់នៅរស់នោះដែរ ។

សហព្រះរាជអជ្ញាបានបង្ហាញ

និងអានកថាខណ្ឌមួយចំនួនជូនសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនៅត្រង់ ជំពូកមួយដែលមានចំណងជើងថា “ពិចារណាឡើងវិញពីតួនាទីរបស់មេដឹកនាំ និងកម្មាភិបាលថ្នាក់ក្រោមនៃរបបកម្ពុជាប្រជាធិបតេយ្យ ៖ ការទួលខុសត្រូវរបស់ខ្មែរក្រហម” ដែលសរសេរឡើងដោយសាក្សីផ្ទាល់ ។ ចំណុចដកស្រង់នេះនិយាយអំពីក្រុមមួយចំនួន ដែលមិនស្ថិតនៅក្នុងវណ្ណៈរបស់ខ្មែរក្រហម ។ ក្រុមទាំងនោះរួមមានព្រះសង្ឃ ក្រុមជនជាតិភាគតិច និងសាសនិកជន ។ ព័ត៌មាននេះដកស្រង់ចេញពីសៀវភៅកំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហមពីរនាក់ដែលពុំមានឈ្មោះ ហើយសាក្សីបានជម្រាបជូនតុលាការថាសៀវភៅទាំងនេះមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

សហព្រះរាជអជ្ញាបាន បង្ហាញឯកសារដែលសាក្សីលើកឡើងកាលពីថ្ងៃដំបូងដែលខ្លួនបានផ្តល់សក្ខីកម្ម ។ អ្នកដែលផ្តល់បទសម្ភាសន៍នោះ គឺជាអនុលេខាតំបន់នៅសម័យខ្មែរក្រហម ដែលបានអង្កេត ហើយនៅចាំថា ប៉ុល ពត បានធ្វើការកែប្រែគោលនយោបាយសន្តិសុខ ។ “បញ្ហាវណ្ណៈ” បានក្លាយទៅជាបញ្ហាសំខាន់បំផុតនៅក្នុងសង្គម ហើយជាក់ស្តែង ខ្មែរក្រហមឲ្យតម្លៃវណ្ណៈកសិករនិងកម្មករជាងវណ្ណៈទាំងប្រាំនៅក្នុងសម័យនោះ ។

លោក ហេដឌ័រ បានអះអាងថា ឯកសារនេះពិតជាត្រឹមត្រូវ ប៉ុន្តែការបកប្រែវិញហាក់បីដូចជាឆ្គង ។

បន្ទាប់ពីបានសន្យាថានឹងថតចម្លងបទសម្ភាសន៍ជាភាសាខ្មែរ សហព្រះរាជអជ្ញា រេយន័រ លើកឡើងនូវសម្រង់អត្ថបទមួយទៀត ដែលនិយាយអំពីកង្វល់របស់ខ្មែរក្រហមទៅលើក្រុមផ្សេងទៀតដែល “កំពុងតែធ្វើសកម្មភាព” នៅក្នុងសង្គម ។ អ្នកដែលផ្តល់បទសម្ភាសន៍ម្នាក់បានលើកឡើងថា ខ្មែរក្រហមបានកម្ទេចវត្តអារាម និងផ្សឹកព្រះសង្ឃក្រោយពេលឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ។ ខ្មែរក្រហម

ប្រាប់ឈ្លើយសឹកសង្គ្រាមនិងជនផ្តាច់ខ្លួនថាអ្នកទាំងនោះអាចរស់នៅក្រោមដែនកំណត់មួយចំនួន ។ ប៉ុន្តែក្រោយមក ខ្មែរក្រហមបានកម្ទេចអ្នកទាំងនោះចោលទៅវិញ ។

នៅពេលដែលពិនិត្យមើលឯកសារថតចម្លងជាភាសាខ្មែរ ដែលសហព្រះរាជអជ្ញាបង្ហាញជូនលោក ហេដឌ័រ លើកឡើងថា ការគាបសង្កត់លើប្រជាជនដែលរៀបរាប់នៅក្នុងឯកសារនោះ គឺពិតជាបានកើតឡើងនៅក្នុងសង្គមចាស់ប៉ុណ្ណោះ ប៉ុន្តែពុំមែននៅក្នុងរបបខ្មែរក្រហមនោះទេ ។ ចំពោះឯកសារដកស្រង់ទីពីរដែលបកប្រែថា “បោសសម្អាត” ប្រជាជនសាក្សីបានបញ្ជាក់ថាពាក្យនេះមានន័យស្មើនឹង “កម្ទេច» ។

ព្រះរាជអជ្ញាអានបទសម្ភាសន៍ជាមួយអតីតទាហានខ្មែរក្រហម ដែលនិយាយអំពីការចេញបញ្ជាឲ្យវាយសម្រុកគ្រប់មុខព្រួញទាំងអស់ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៧៥ ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៥ សេចក្តីណែនាំឲ្យសាងសង់ផ្ទះជូនប្រជាជនជម្លៀសទាំងអស់ត្រូវបានផ្សព្វផ្សាយដល់គ្រប់តំបន់ទាំងអស់ ។

បន្ទាប់មកទៀត សហព្រះរាជអជ្ញាបានបន្តសួរដេញដោលសាក្សីអំពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋ និងការបញ្ជារបស់ខ្មែរក្រហម ។ សហព្រះរាជអាជ្ញាបានអានការដកស្រង់មួយចេញពីសៀវភៅរបស់លោក ប៉ែន យៀនិន ដែលមានចំណងជើងថា “ការរើសអើងជាតិសាសន៍ លទ្ធិមាក ការបែងចែកក្រុម និងអំពើប្រល័យពូជសាសន៍» ។ ការដកស្រង់នេះបានលើកឡើងថា រចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចគ្នាទៅនឹងរចនាសម្ព័នបក្សកុម្មុយនីស្តចិន និងវៀតណាមដែល“គណៈមជ្ឈិម” ជាថ្នាក់ដឹកនាំខ្ពស់បំផុតរបស់បក្ស ។ នៅពេលសួរថាតើ“មជ្ឈិមបក្ស” មានន័យដូចគ្នានឹងគណៈមជ្ឈិមបក្សដែរឬទេ? សាក្សីបានឆ្លើយតបថា គណៈមជ្ឈិមបក្សគ្រាន់តែជាផ្នែកមួយក្នុងចំណោមផ្នែកជាច្រើនទៀតដែលបង្កើតបានជាបក្សកុម្មុយនីស្តរបស់ខ្មែរក្រហម ។

សហព្រះរាជអជ្ញា រេយន័រ បានបន្តការចោទសួរដោយលើកយកសៀវភៅរបស់លោក ហេដឌ័រ មានចំណងជើងថា “*បេក្ខជនប្រាំពីរដែលត្រូវនាំមកកាត់ទោស*” ។ នៅពេលដែលសហព្រះរាជអជ្ញា កំពុងចោទសួរសាក្សី លោក វ៉ិចទ័រ កុបប៉េ ដែលជាសហមេធាវីអន្តរជាតិការពារក្តី នួន ជា បានស្នើរសុំឲ្យមានការសម្រេចពីតុលាការ ដោយសារតែចំណងជើងសៀវភៅនេះ មានចេតនាបង្ហាញអំពីភស្តុតាងដាក់បន្ទុកទៅលើជនជាប់ចោទ ខៀវ សំផន និង នួន ជា ។ លោកបានអះអាងទៀតថាតុលាការគួរតែធ្វើការបដិសេធចំពោះការលើកឡើងរបស់សហព្រះរាជអជ្ញា ដោយហេតុថា “សាក្សីមានតួនាទីយ៉ាងសំខាន់នៅក្នុងអង្គភាពសហព្រះរាជអជ្ញា ដូច្នេះការសួរសំនួរទាក់ទងនឹងសៀវភៅនេះធ្វើឡើងដើម្បីដាក់បន្ទុកមកលើកូនក្តីរបស់យើង» ។

សហព្រះរាជអជ្ញា រេយន័រ បានបញ្ជាក់ថាខ្លួននឹងមិនស្នើរសុំយោបល់របស់សាក្សីនោះទេ ហើយសៀវភៅទាំងនេះត្រូវបានដាក់បញ្ចូលជាភស្តុតាងរួចទៅហើយ ។

ចៅក្រម ស៊ីលវៀ ខាតវ្រ៉ាយត៍ បានសម្រេចថា ការជំទាស់នេះពុំមានប្រសិទ្ធភាព ដោយហេតុថា សៀវភៅនេះត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយ ម្យ៉ាងទៀតមានតែអង្គជំនុំជម្រះតែមួយគត់ដែលជាអ្នកចេញសេចក្តីសម្រេចលើការទទួលយកបាននៃភស្តុតាង ។

សហព្រះរាជអជ្ញាបានបន្តសួរលោក ហេដឌ័រ អំពីលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ។ សាក្សី បានជម្រាបអង្គជំនុំជម្រះថា តាមដែលលោកបានដឹង គឺមានតែឯកសារថតចម្លង និងឯកសារច្បាប់ដើមនេះប៉ុណ្ណោះ ដែលនិយាយទាក់ទងនឹងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយពុំមានឯកសារណាផ្សេងទៀតនោះទេ ។ តាមរយៈបទសម្ភាសន៍របស់ខ្លួន សាក្សីយល់ថា លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានខ្មែរក្រហមអនុម័តកាលពីខែមករា ឆ្នាំ១៩៧៦ ។

នៅជំពូកមួយនៃសៀវភៅដែលមានចំណងជើងថា «ពិចារណាឡើងវិញអំពីតួនាទីរបស់មេដឹកនាំ និងកម្មាភិបាលថ្នាក់ក្រោមនៃរបបកម្ពុជាប្រជាធិបតេយ្យ ៖ ការទទួលខុសត្រូវរបស់ខ្មែរក្រហម» លោក ហេដឌ័រ បានសរសេរថា ភូមិភាគ និងតំបន់មានតួនាទីភ្ជាប់ទំនាក់ទំនងរវាងស្រុក និងមជ្ឈិម ។ សាក្សីបានបញ្ជាក់ទៀតថា លេខាភូមិភាគ និងតំបន់ចូលរួមប្រជុំជាមួយ នួន ជា និង ប៉ុល ពត ហើយព័ត៌មាននេះ ត្រូវបានដកស្រង់ចេញពីបទសម្ភាសន៍ជាមួយ កែ ពក ។ កែ ពក បានយល់ព្រមផ្តល់បទសម្ភាសន៍ជាមួយ លោក ហេដឌ័រ នៅក្នុងលក្ខខ័ណ្ឌមួយដែលព័ត៌មានទាំងនោះនឹងមិនត្រូវផ្សព្វផ្សាយឡើយដរាបណា កែ ពក នៅមានជីវិតនៅឡើយ ។ កែ ពក បានអះអាងថាគាត់បានអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដោយសម្លាប់មន្ត្រីរដ្ឋការ លន់ នល់ ។ នួន ជា ជាអ្នកចេញបញ្ជាឲ្យធ្វើការស៊ើបអង្កេតទៅលើអតីតរដ្ឋការ លន់ នល់ ។ គាត់លើកឡើងថែមទៀតថា នួន ជា បានដឹងរួចជាស្រេចថាអ្នករដ្ឋការនៅក្នុងរបប លន់ នល់ នឹងត្រូវយកទៅសម្លាប់ ។

នៅចំពោះមុខអង្គជំនុំជម្រះ លោក ហេដឌ័រ បានលើកឡើងថា កែ ពក ជាលេខាភូមិភាគឧត្តរ ហើយ ក្រោយមកជាលេខាភូមិភាគមជ្ឈិម ។ កែ ពក ជាសមាជិកម្នាក់របស់គណៈមជ្ឈិមបក្ស ប៉ុន្តែក្រោយមកក៏ធ្លាក់ពីតំណែងជាសមាជិកមជ្ឈិមបក្សនៅក្រោយខែមករា ឆ្នាំ១៩៦៩ ។ សាក្សី បានបញ្ជាក់ថា ក្រោយមក កែ ពក ក៏បានកាយជាមន្ត្រីយោធារដ្ឋាភិបាលបន្ទាប់ពីការរដួលរលំរបបខ្មែរក្រហម ។ លោក ហេដឌ័រ បានកត់ត្រាបទសម្ភាសន៍នេះទុក ប៉ុន្តែ កំណត់ត្រារបស់លោកមិនស្ថិតនៅក្នុងប្រទេសកម្ពុជានោះទេ ដោយហេតុថាលោករក្សាទុកកំណត់ត្រាទាំងអស់នោះនៅទីក្រុងឡុងដ៍ ។

សហព្រះរាជអាជ្ញា រេយន័រ បានបន្តសួរសាក្សីថាតើការជ្រើសរើសកំណត់ហេតុទាំងនោះមកតុលាការអាចបង្កផលវិបាកយ៉ាងណាខ្លះដល់សាក្សីផ្ទាល់ ។

សហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរសាក្សីទាក់ទងទៅនឹងព័ត៌មាននៅក្នុងជំពូកដដែរ ហើយសាក្សីជម្រាបជូនតុលាការអំពីវិធី ដែលលេខាភូមិភាគធ្វើការរាយការណ៍យ៉ាងលម្អិតទៅមជ្ឈិមបក្សអំពីសភាពការណ៍នៅក្នុងតំបន់ដែលខ្លួនគ្រប់គ្រងចាប់ពីថ្នាក់លើរហូតដល់ថ្នាក់មូលដ្ឋាន ។ ទាក់ទងនឹងសារទូរលេខ ខ្មែរក្រហម លោក ហេដឌ័រ បានរៀបរាប់ជូនតុលាការថាខ្លួនបានពិនិត្យឯកសារទាំងនេះដំបូងបំផុតនៅមជ្ឈមណ្ឌលឯកសារកម្ពុជានៅទសវត្សឆ្នាំ១៩៩០ ។

សហព្រះរាជអាជ្ញា បានបញ្ជាក់ពីវិធីដែលខ្មែរក្រហមបញ្ជូនរបាយការណ៍របស់ខ្លួនទៅថ្នាក់លើតាមរយៈបទសម្ភាសន៍ដែលសាក្សីប្រមូលបាន ដោយអនុវត្តគោលនយោបាយផ្លូវការមួយរបស់គាត់ ។ នៅពេលដែលសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីពីចំនុចនេះ លោក គុប ប៉េ ធ្វើការជំទាស់ដោយអះអាងថា ការសួររបស់សហព្រះរាជអាជ្ញាហាក់បីដូចជាសាក្សីរូបនេះជាសាក្សីជំនាញ ប៉ុន្តែ តែការជំទាស់នេះមិនមានប្រសិទ្ធភាពនោះទេ ។

លោក ហេដឌ័រ បានធ្វើការបកស្រាយអំពីសន្ទរកថារបស់ ប៉ុល ពត នៅឆ្នាំ១៩៧៦ ព្រមទាំងសរសេរនៅក្នុងសៀវភៅខ្លួនអំពីទំនួលខុសត្រូវរបស់លេខាភូមិភាគក្នុងការធានាឲ្យស្រុក និងតំបន់ដែលខ្លួនគ្រប់គ្រង អនុវត្តតាមមាគ៌ាបក្សដែលបង្កើតឡើងដោយថ្នាក់មជ្ឈិម ។ តាមរយៈព័ត៌មាននៅក្នុងបទសម្ភាសន៍ ជាមួយ កែ ពក លោក ហេដឌ័រ បានសរសេរអំពីកិច្ចប្រជុំ និងការរាយការណ៍ជូនគ្នាទៅវិញទៅវិញ និងជាញឹកញាប់រវាង ប៉ុល ពត និង លេខាតំបន់ និងភូមិភាគ ។

សហព្រះរាជអាជ្ញាអន្តរជាតិ រេយន័រ បានដកស្រង់ប្រធានបទថ្មីមួយទៀតពីសៀវភៅរបស់លោក ហេដឌ័រ ដោយផ្តោតទៅលើពាក្យថា "ខ្មាំង" ។ នៅក្នុងបទសម្ភាសន៍ដែលធ្វើឡើងថ្ងៃទី១៦ ខែមិនា ឆ្នាំ១៩៨០ អតីតនាយទាហានម្នាក់បានប្រាប់លោក ហេដឌ័រ ថា "នៅឆ្នាំ១៩៧២ ទាហាន នល់ នល់ ប្រហែលជា ៥០០នាក់ ត្រូវបានចាប់ខ្លួន។ ទាហានទាំងអស់ត្រូវបានយកទៅសម្លាប់ ហើយពុំមានទាហានណាមួយរស់រានមានជីវិតពីការសម្លាប់នោះឡើយ ។

នាយទាហានម្នាក់នេះបានលើកឡើងទៀតថា "ខ្សែសង្វាក់សង្វាក់" របស់កម្មាភិបាលខ្មែរក្រហមចាប់ពីថ្នាក់លើរហូតដល់ថ្នាក់ក្រោមបំផុតត្រូវបានចាប់ខ្លួន ។ នាយទាហាននេះបានបន្តទៀតថាប្រជាជនបានដឹងអំពីរឿងរ៉ាវអាក្រក់ជាច្រើនដែលកំពុងកើតឡើង ប៉ុន្តែប្រជាជនទាំងនោះពុំហ៊ានធ្វើសកម្មភាពប្រឆាំងនោះទេ ។ ទាហានរូបនេះ បាននិយាយបន្តទៀតថា អ្នកដែលត្រូវបានចាប់ខ្លួនត្រូវនាំយកទៅរៀនសូត្រ ហើយបានបាត់ខ្លួនតែម្តង ។ ខ្មែរក្រហមក៏បានប្រើវិធីនេះជាមួយនឹងមន្ត្រី លន់ នល់ នៅ

ឆ្នាំ១៩៧៥ ដោយសន្យាថានឹងលើកលែងទោសឲ្យអ្នកទាំងនោះបន្ទាប់ពីទៅរៀនសូត្ររួច ប៉ុន្តែជាក់ស្តែងមន្ត្រី លន់ នល់ ទាំងអស់នោះក៏បាត់ខ្លួន ។

នៅមជ្ឈិម«កងកម្លាំងពិសេស» ទទួលខុសត្រូវខាងបោសសម្អាតនេះ បើយោងតាមការរៀបរាប់របស់អតីតនាយទាហានរបស់បក្សកុម្មុយនីស្តម្នាក់ឈ្មោះ នួន សួន ដែលធ្លាប់ធ្វើជាប្រធានគណៈទទួលបន្ទុកខាងផ្នែកកសិកម្មចាប់តាំងពីឆ្នាំ១៩៧៥មក ។

នៅម៉ោងសម្រាកពេលព្រឹក សហព្រះរាជអជ្ញាបានស្នើរសុំឲ្យ លោក ហេដឌ័រ បញ្ជាក់អំពីអត្តសញ្ញាណ អ្នកដែលផ្តល់បទសម្ភាសន៍ ដោយសារឈ្មោះដែលសរសេរនៅលើបទសម្ភាសន៍នោះទំនងជាជាខុស ។ បន្ទាប់ពីការសម្រាក សាក្សីក៏បញ្ជាក់ថាឈ្មោះនោះពិតជាត្រឹមត្រូវមែន ។ ឈ្មោះរបស់គាត់គឺ ម៉ាត់ លី ។ ម៉ាត់ លី ធ្លាប់ធ្វើជាសមាជិកគណៈកម្មាធិការស្រុក និងសមាជិកគណៈកម្មាធិការមជ្ឈិម ។

នៅក្នុងបទសម្ភាសន៍នេះ លោក ម៉ាត់ លី បានរាយការណ៍ថា «គោលការណ៍សំខាន់ គឺដកស្មៅត្រូវដកទាំងឬស» ដោយសំដៅទៅលើការជម្លៀសប្រជាជន១៧មេសាឲ្យអស់ពីទីក្រុង ។ លោក ម៉ាត់ លី បានលើកឡើងថា ខ្មែរក្រហមបានស្រាវជ្រាវរកប្រជាជនថ្មី ហើយប្រសិនបើប្រជាជនថ្មីនោះជាអនុសេនីយ៍ទោ ឬធ្លាប់ធ្វើការនៅក្នុងតុលាការ ខ្មែរក្រហមនឹងសម្លាប់ចោលភ្លាម ។ ដូចគ្នាដែរ ម៉ាត់ លី បានបន្ថែមទៀតថា ខ្មែរក្រហមបានចោទប្រកាន់ប្រជាជនថាជាចារកិច្ចយួន ឬជាភ្នាក់ងារ សេ.អ៊ី.អា និង កា.ហ្សេ.បេ ហើយអ្នកទាំងនោះត្រូវយកទៅសម្លាប់ ។ ខណៈពេលដែលលោក ហេដឌ័រ សួរ ម៉ាត់ លី ថាតើមានវិធីណាដែលអាចជួយមិនឲ្យការសម្លាប់នោះកើតឡើងដែរឬទេ? លោក ម៉ាត់ លី ឆ្លើយតបថា នៅពេលដែលគាត់សួរខ្មែរក្រហមអំពីមូលហេតុដែលនាំឲ្យមានការសម្លាប់មនុស្ស ខ្មែរក្រហមបានឆ្លើយបានប្រាប់គាត់វិញថា អ្នកដែលត្រូវយកទៅសម្លាប់ទាំងអស់នោះសុទ្ធតែជាខ្សែរបស់ សេ.អ៊ី.អា និង កា.ហ្សេ.បេ ។ តាមការលើកឡើងរបស់ ម៉ាត់ លី ចាប់ពី១៩៧៥មក ការសម្លាប់កើនឡើងជាបន្តបន្ទាប់ ។ គាត់បាននិយាយទៀតថា «ប្រសិនបើសម្លាប់តែយុវជន អ្នកចេះដឹង និងអ្នកដែលពិតជាបានធ្វើជាភ្នាក់ងារសម្ងាត់មែននោះ យើងមិនថាអ្វីនោះទេ ។ ប៉ុន្តែនៅពេលដែលខ្មែរក្រហមស៊ើបដឹងថាអ្នកណាជាគ្រូបង្រៀន វេជ្ជបណ្ឌិត និងអ្នកចេះដឹង ខ្មែរក្រហមនឹងសម្លាប់អ្នកទាំងអស់នោះភ្លាម» ។

បទសម្ភាសន៍នេះលើកឡើងអំពីវិធីសាស្ត្រដែលខ្មែរក្រហមបោកប្រាស់ប្រជាជនដោយប្រកាសថាប្រសិនបើអ្នកណាសារភាពពីមុខដំណែងរបស់ខ្លួននៅរបបមុន អ្នកទាំងនោះនឹងត្រូវបានចាត់តាំងឲ្យទៅ

កាន់តំណែងដើមវិញ នៅក្រោមការគ្រប់គ្រងនៃរបបថ្មីៗ ម៉ាត់ លី បានអះអាងថា «ការធ្វើប្រវត្តរូបគឺជាការអត្តឃាតខ្លួនឯងតែម្ដង» ។

ម៉ាត់ លី បន្តលើកឡើងអំពីការបាត់ខ្លួនរបស់ជនជាតិចាម ប៉ូលីស ទាហាន និងកម្មាភិបាលខ្មែរក្រហម ។

សហព្រះរាជអជ្ញាបានអានបទសម្ភាសន៍មួយទៀត ដែលបញ្ជាក់បន្ថែមទៅលើការអះអាងខាងលើជូនសាក្សី ។ បទសម្ភាន៍នេះលើកឡើងថាថា «នៅភូមិភាគឧត្តរមានមនុស្សជាច្រើនត្រូវបានសម្លាប់នៅក្រោយឆ្នាំ១៩៧៥ ហើយការជម្លៀសប្រជាជននៅខេត្តបាត់ដំបង មិនទាន់ធ្វើបានចប់សព្វគ្រប់នៅឡើយទេ ខណៈពេលដែលកម្មាភិបាលនៅភូមិភាគឧត្តរចាប់ផ្ដើមសម្លាប់ប្រជាជនជាខ្មែរៗ ដោយរួមអ្នករដ្ឋការលន់ នល់ និងទាហាន លន់ នល់ និងប្រជាជន ។

តាមរយៈបទសម្ភាសន៍ជាមួយនឹងអនុប្រធានតំបន់២១ លោកហេដឌ័រ បានដឹងថា ប៉ុល ពត បានចេញគោលនយោបាយសម្ងាត់ ដែលបង្កឲ្យមាន«ការបោសសម្អាតអតីតសមាជិកនៃរបប លន់ នល់» ។ សហព្រះរាជអជ្ញា រេយន័រ បានអានការដកស្រង់ពីសម្ភាសន៍នេះនៅចំពោះមុខអង្គជំនុះជម្រះ ហើយបញ្ជាក់ថា ការបកប្រែរបស់តុលាការគឺត្រឹមត្រូវ ដោយសាក្សីអះអាងថា ពាក្យ«ដកចេញ» មានន័យដូចគ្នានឹងពាក្យ «បោសសម្អាត» ។

អនុលេខាតំបន់២១ បានបន្តរពិភាក្សាអំពីវិធីសាស្ត្រដែលខ្មែរក្រហមអនុវត្តដើម្បីដកអ្នកដែលធ្លាប់ធ្វើ ការបម្រើរបបមុនចេញពីគ្រប់ផ្នែកទាំងអស់ ដូចជានៅក្នុងបក្សនិងនៅក្នុងជួរកងទ័ព ។ វិធីសាស្ត្រនេះគឺជាគោលនយោបាយមួយដ៏សំខាន់របស់បក្ស ។

លោក ហេដឌ័រ បានបញ្ជាក់ថា ពាក្យ«បុណ្យសក្តិ» សំដៅទៅលើអ្នករដ្ឋការរបប លន់ នល់ ដែល មានពាក់ឯកសណ្ឋាននិងសញ្ញាសំគាល់ពីឋានន្តរសក្តិ ។

សហព្រះរាជអជ្ញាអាន ការដកស្រង់យ៉ាងវែងមួយពីសៀវភៅរបស់លោក ហេដឌ័រ ចំពោះមុខអង្គជំនុំជម្រះដើម្បីបង្ហាញអំពីឋានៈសង្គមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ៖

> ទាក់ទងទៅនឹងវិធានការណ៍សន្តិសុខនៅក្នុងសង្គម ខ្មែរក្រហមបានបែងចែកប្រជាជនជាបីក្រុម គឺក្រុម«ពេញសិទ្ធ» «ត្រៀម» និង «បញ្ញើរ» ។ ប្រព័ន្ធនៃការបែងចែកនេះសំដៅទៅលើសិទ្ធរបស់ក្រុម ដែលជាសមាជិកនៅក្នុងសហករណ៍ ហើយការប្រើប្រាស់ពាក្យនីមួយទៅលើក្រុមផ្សេងគ្នានេះធ្វើឡើង ដោយសំអាងទៅលើ តើអ្នកណាខ្លះមានភក្តីភាពជាមួយនឹងបដិវត្តន៍ឬមានចិត្តក្បត់ ។ អ្នកដែលស្ថិតនៅក្រុមទាបជាងគេ

បន្ទុស់ ក្រុមបញ្ញើរ មិនត្រឹមតែទទួលរងការរើងអើងនោះ តែថែមទាំងមិនមានសិទ្ធសេរីភាព និងត្រូវយកទៅសម្លាប់ចោលទៀតផង ។ ដូច្នេះ និយាយជាទូទៅ អ្នកដែលនៅក្នុងក្រុមទីមួយរបស់របបកម្ពុជាប្រជាធិបតេយ្យ គឺប្រជាជនពេញសិទ្ធ ជាក្រុមដែលទទួលបានរបបអាហារ គ្រប់គ្រាន់ និង មានសិទ្ធិចូលរួមធ្វើនយោបាយ ដូចជាសមាជិកបក្ស កងទ័ព និងមានសិទ្ធិកាន់មុខ ដំណែងផ្សេងៗទៀត ។

លោក ហេដឌ័រ បានសរសេរថា នៅទីបំផុត ប៉ុល ពត បានលុបបំបាត់ការបែងចែកនេះ ដោយលើកហេតុផលថា មានតែ«ប្រជាជនមូលដ្ឋាន» ដែលចូលធ្វើបដិវត្តនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និង«ប្រជាជនថ្មី» ដែលចូលបដិវត្តន៍នៅក្រោយថ្ងៃ១៧ មេសា ។

លោក កូប៉េ បានបន្តធ្វើការជំទាស់នឹងការលើកឡើងនេះ ដោយលើកហេតុផលថា ការលើកឡើងរបស់សហព្រះរាជអជ្ញា នឹងនាំឲ្យសាក្សីផ្តល់សក្ខីកម្មទៅលើចំនុចដែល«មិនអាចទទួលយកបានទាល់តែសោះ» ដោយសារតែសាក្សីធ្លាប់ធ្វើការនៅក្នុងការិយាល័យសហព្រះរាជអជ្ញា ។ សហព្រះរាជអជ្ញាកំពុងតែអានកថាខណ្ឌដែលដកស្រង់ចេញពីសៀវភៅរបស់លោក ហេដឌ័រ ដែលមានចំណងជើងថា បេក្ខជនប្រាំពីររូបសម្រាប់នាំមកកាត់ទោស ។

លោក អាកទូរ វែកគែន សហមេធាវីការពារក្តីរបស់ ខៀវ សំផន ក៏ជំទាស់នឹងការលើកលែងរបស់សហព្រះរាជអជ្ញា ដោយលើកឡើងសហព្រះរាជអជ្ញាកំពុងធ្វើការដេញដោលអំពីឯកសារសំខាន់ដែលគាត់បានជំទាស់រួចទៅហើយ ។ សាក្សីធ្វើដំណើររាប់ពាន់ម៉ៃមកទីនេះដើម្បីឲ្យសហព្រះរាជអជ្ញាអានសៀវភៅរបស់គាត់ ។ លោក អាកទូរ វែកគែន សួរថា «តើការសាក់សួរសាក្សីមានន័យដូចម្តេចទៅ? »

សហព្រះរាជអជ្ញា រេយន័រ បានធ្វើការឆ្លើយតបភ្លាមថា «ប្រសិនបើមេធាវីការពារក្តីចង់ឲ្យខ្ញុំផ្តល់មេរៀនខ្លះដល់គាត់ទាក់ទងនឹងការសាកសួរសាក្សី ខ្ញុំនឹងធ្វើភ្លាម» ។ អង្គជំនុំជម្រះអនុញ្ញាតឲ្យសហព្រះរាជអជ្ញា រេយន័រ បន្តសួរសាក្សីហើយច្រានចោលសំណើរជំទាស់ទាំងពីររបស់សហមេធាវីការក្តី ។

សហព្រះរាជអជ្ញា រេយន័រ បន្តរអានកថាខណ្ឌពីសៀវភៅលោក ហេដឌ័រ ដោយផ្តោតទៅលើចំនុចដែលលើកលើងថា ប្រជាជនថ្មីធ្លាប់រស់យ៉ាងសុខស្រួលនៅពេលបដិវត្តន៍ ដូច្នេះក្រុមនេះមានគោលជំហរពឹងពាក់ច្រើន និងអាចរួមគ្នាធ្វើការបះបោលប្រឆាំងនឹងបដិវត្តន៍ ដោយធ្វើតាមបញ្ជារបស់ សេ.អ៊ី.អា. ។ ខ្មែរក្រហមចាត់ទុកប្រជាជនថ្មី«ជាកំអែលរបបចាស់» ។ សាក្សីពន្យល់ថា ជាភាសារខ្មែរ ពាក្យនេះសំដៅទៅលើស្បែកដែលយើងត្រូវបោសសម្អាតចោលដើម្បីឲ្យអស់ធូលី ។

ទាក់ទងទៅនឹងការសម្លាប់អ្នករដ្ឋការ លន់ នល់ ឬអ្នកមានបុណ្យសក្តិ សាក្សីរាយការណ៍ជូនតុលាការពីការបកស្រាយរបស់ កែ ពក ។ កែ ពក អះអាងថាគោលនយោបាយនេះមានសារៈសំខាន់សម្រាប់បោសសម្អាតកំអែលរបបចាស់ ។ យោងតាមឯកសារដែលចងក្រងដោយ កេន អ៊ុន ប៉ុល ពត ណែនាំឲ្យកម្មាភិបាលខ្មែរក្រហមប្រកាន់“ជំហរយ៉ាងមុតមាំ” ប្រឆាំងជាមួយសត្រូវកំអែររបស់របបមុន ។

សារទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក មានចំណងជើងថា “ប្រព័ន្ធសន្តិសុខនៅកម្ពុជា” បញ្ជាក់ថា ប្រធានសហករណ៍ជាអ្នកធ្វើការសម្រេច តើអ្នកណាម្នាក់ត្រូវយកទៅរៀនសូត្រនៅមូលដ្ឋាន ឬត្រូវបញ្ជូនទៅគណៈកម្មាធិការសន្តិសុខថ្នាក់ស្រុកដើម្បីស៊ើបអង្កេតបន្ត ។ បន្ទាប់មក គណៈកម្មាធិការសន្តិសុខថ្នាក់ស្រុកជាអ្នកសម្រាច់ថាត្រូវសម្លាប់ ឬក៏ឃុំខ្លួនបន្ត ។

សហព្រះរាជអាជ្ញាចោទសួរលោក ហេដឌ័រ ថាតើគាត់ដែលបានពិនិត្យមើលបទសម្ភាសន៍ណាដែលខ្មែរក្រហមបានអនុវត្តន៍ដូចគ្នានឹងការលើកឡើងនៅក្នុងរបាយការណ៍ “ប្រព័នសន្តិសុខនៅកម្ពុជា” របស់ក្រសួងការបរទេស ។ សាក្សីបញ្ជាក់ថា គោលនយោបាយ និងការអនុវត្តន៍ជាក់ស្តែងមានភាពខុសគ្នា ហើយជាធម្មតា សេចក្តីសម្រេចមិនបានបញ្ជូនទៅដល់ថ្នាក់ភូមិភាគនោះទេ ។

លោក ហេដឌ័រ បញ្ជាក់ជូនតុលាការថា នៅក្នុងករណីខ្លះខ្មែរក្រហមអនុវត្តតាមនីតិវិធីនេះ នៅពេលដែលធ្វើការតាមដានលើប្រជាជនថ្មី ហើយនៅក្នុងករណីខ្លះទៀត ខ្មែរក្រហមមិនបានអនុវត្តន៍តាមវិធីសាស្រ្តនេះទេ ។ សាក្សីនៅចាំថា នៅពេលដែលសាក្សីសួរលោក អៀង សារី ថាតើគាត់ដែលបានទទួលរបាយការណ៍ទាក់ទងនឹងការសម្លាប់មនុស្សពីភូមិភាគនិងតំបន់ដែរឬទេ អៀង សារី សារភាពថាគាត់បានទទួលការស្នើរសុំមួយចំនួន ប៉ុន្តែវាកម្របំផុត ។

យោងតាមសៀវភៅកំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហមពីរនាក់ ដែលបានលើកឡើងរួចមកហើយ សាក្សីសរសេរនៅក្នុងសៀវភៅរបស់គាត់ថា ខ្មែរក្រហមចាត់ទុកលោកព្រះសង្ឃថ្នាក់លើជាអ្នកមានបុណ្យសក្តិ ដែលត្រូវយកទៅសម្លាប់ ។ សាក្សីបានសរសេរបញ្ជាក់បន្ថែមថា ជាក់ស្តែង បើយោងតាមកិច្ចប្រជុំថ្នាក់លេខាតំបន់ និងអនុលេខា អ្នកដែលចាត់ទុកថាធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ត្រូវយកទៅសម្លាប់ ។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ លេខា និងអនុលេខាតំបន់បានទទួលការណែនាំឲ្យចាត់វិធានធ្វើយ៉ាងកម្ទេចចោលឲ្យអស់ “សមាសភាពមិនល្អ” ។

នៅត្រង់ចំនុចនេះ លោក កូប៉េ ធ្វើការជំទាសម្តងទៀត ដោយអះអាងថា សាក្សីកំពុងតែផ្តល់សក្ខីកម្មដូចជាសាក្សីជំនាញ ។ អង្គជំនុំជម្រះមិនសម្រេច“ច្រានចោលទាំងស្រុង” នូវការជំទាស់របស់

មេធាវីការពារក្តី ប៉ុន្តែ ចៅក្រម ខាតព្រ៊ាយត៍ គាំទ្រថាសាក្សីមិនមានធ្វើការវិភាគផ្ទាល់ជូនតុលាការនោះទេ ។

នៅក្នុងសៀវភៅ បេក្ខជនប្រាំពីរនាក់ដែលត្រូវនាំមកកាត់ទោស លោក ហេដឌ័រ បានសរសេរថា នៅក្នុងកិច្ចប្រជុំមួយនៅឆ្នាំ១៩៧៦ សុន សាន ផ្តល់យោបល់ថាយើងត្រូវតែកម្ទេចចោលឲ្យអស់ខ្មាំងទាំងឡាយណាដែលធ្វើសម្មភាពប្រឆាំងនឹងបដិវត្តន៍ មិនថាជាសកម្មភាពនោះតូចតាចឬមិនសូវសំខាន់យ៉ាងណាក៏ដោយ ឲ្យតើបផ្អាក់ផែនការរបស់បក្ស ។ សកម្មភាពតូចតាចទាំងនោះមានចាប់ពីការបន្ទោរបង់នៅចំផ្លូវដើរ និងការគោះទ្វាផ្ទះនៅពេលយប់ជាដើម ។

បន្ទាប់ពីម៉ោងសម្រាកពេលរសៀក សាក្សីលើកឡើងថា គាត់បានដឹងថាប្រជាជនត្រូវយកទៅសម្លាប់ សូម្បីតែអ្នកទាំងនោះគ្រាន់ធ្វើបាក់ប៉ែល ឬក្តិចលេងជាមួយអ្នកផ្សេង ។

តុលាការបន្តសោកសួរពីឯកសារបោះពុម្ពផ្សាយមួយទៀត ដែលសាក្សីសរសេរនៅឆ្នាំ១៩៩១ ទាក់ទងនឹង “ប៉ុល ពត និង ខៀវ សំផន” ។ សាក្សីសរសេរអត្ថបទនេះ នៅពេលដែលគាត់ធ្វើការស្រាវជ្រាវនៅសកលវិទ្យាល័យជាតិអូស្ត្រាលី ។

សហព្រះរាជអជ្ញា រាយន័រ អានកថាខណ្ឌមួយដែលដកស្រង់ចេញពីអត្ថបទរបស់សាក្សី មានចំណងជើងថា “ការគិតអំពីអតីតកាល ម៉ៃឃើល វិខរីបានរាយការណ៍ផងដែរថាអ្នកចេះដឹងកម្ពុជាត្រូវបានទាក់ទាញឲ្យធ្លាក់ទៅអសន្តិសុខនៅក្រោមការគ្រប់គ្រងរបស់ ខៀវ សំផន” ។ សាក្សីបានសម្ភាសមនុស្សម្នាក់ដែលបានប្រាប់គាត់ថា បើទោះបីជានៅឆ្នាំ១៩៧៥ គាត់នៅតែមានចិត្តស្រឡាញ់បដិវត្តនិង ខៀវ សំផន ហើយមិនមានចិត្តភ័យខ្លាចទាល់តែសោះថានឹងមានអ្វីកើតឡើងនៅពេលខាងមុខ ។

សាក្សីលើកឡើងថាលោក ម៉ៃឃល់ វិខរី ជាអ្នកប្រវត្តិសាស្ត្រកម្ពុជាជើងចាស់ម្នាក់ ហើយការវិភាគរបស់គាត់ គឺដកស្រង់ចេញពីសៀវភៅរបស់លោក ម៉ៃឃល់ វិខរី ។

សហព្រះរាជអជ្ញាអានកថាខណ្ឌដែលបញ្ជាក់ថា អតីតអ្នករដ្ឋការរបបលន់ នល់ និងអ្នកចេះដឹងអ្នកទាំងអស់ស្ថិតនៅ“ក្នុងក្រុមដែលត្រូវសម្លាប់” ក្រោយពេលដែល ខៀវ សំផន ប្រកាសពីរដងថាខ្មែរក្រហមនឹងសម្លាប់ពួកក្បត់ប្រាំពីរនាក់តែប៉ុណ្ណោះ ។ សហព្រះរាជអជ្ញាបន្តអានសេចក្តីប្រកាសរបស់ ខៀវ សំផន ត្រូវបានឲ្យទៅផ្សព្វផ្សាយតាមវិទ្យុ និងលើកទីពីរនៅពេលប្រជុំសមាជជាតិរបស់បក្សកុំម្មុយនីសកម្ពុជា ។

សហព្រះរាជអជ្ញា រាយន័យ បន្តសួរដេញដោលលោក ហេដឌ័រ អំពីវិធីសាស្ត្រនៃការស្រាវជ្រាវ និងប្រភពឯកសាររបស់គាត់ ។ សហព្រះរាជអជ្ញាលើកឡើងថា សាក្សីមិនបានធ្វើការស្រាវជ្រាវលើរបាយការណ៍របស់ភ្នាក់ងារផ្សព្វផ្សាយព័ត៌មានអន្តរជាតិ នៅពេលដែលគាត់ស្នាក់នៅអូស្ត្រាលី ។

របាយការណ៍ទាំងនោះ ជារបាយការណ៍សម្ងាត់នៃផ្សព្វផ្សាយព័ត៌មានបរទេសដែល សេ.អ៊ី.អា បង្ហាញ ចេញជាសាធារណ។ លោក ហេដឌ័ អះអាងថា នៅពេលដែលលោករស់នៅក្នុងប្រទេសកម្ពុជា នៅ ឆ្នាំ១៩៧៥ គាត់ទទួលបានឯកសារទាំងនេះ។ បុគ្គលិកភ្នាក់ងារផ្សព្វផ្សាយព័ត៌មានអន្តរជាតិថតសម្លេង និង ចម្លងការផ្សាយទាំងនោះចេញ ដើម្បីចងក្រងជារបាយការណ៍នៅក្នុងប្រទេសថៃ ហើយក៏គេបញ្ជូន របាយការណ៍ទាំងនោះទៅកាន់ស្ថានទូតអាមេរិក។ លោក ហេដឌ័រ បានអានរបាយការណ៍ទាំងនោះនៅ បន្ទប់ អានឯកសារ នៅក្នុងទីក្រុងភ្នំពេញ និងទស្សនាវដ្ដីដែលមានបញ្ចូលរបាយការណ៍ទាំងនោះដែល បានចែកចាយទៅកាន់បណ្ណាល័យនានានៅជុំវិញពិភពលោក។

លោក ហេដឌ័រ ចាប់ផ្ដើមធ្វើការនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៣ បន្ទាប់ពីគាត់បញ្ចប់ការ សិក្សាបរិញ្ញាប័ត្រខាងការសិក្សាអំពីអាស៊ី នៅសកលវិទ្យាល័យខនែល។ អ្នកការសែតជើងចាស់ម្នាក់ បានប្រាប់ឲ្យគាត់ធ្វើដំណើរមកប្រទេសកម្ពុជា ដោយសារតែមិនមានអ្នកការសែតច្រើនទេដែលរាយ ការណ៍ពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសនេះ។ នៅខែឧសភា ឆ្នាំ១៩៧៣ គាត់មកដល់ ប្រទេសកម្ពុជា និងធ្វើការរាយការណ៍អំពីការសម្រេចរបស់សភាសហរដ្ឋអាមេរិចឲ្យបញ្ឈប់ការទម្លាក់ គ្រាប់បែកនៅកម្ពុជា ដែលបានបញ្ចប់ជាផ្លូវការនៅខែសីហា ឆ្នាំ១៩៧៣។ ពេលនោះ មានការរំពឹង ទុកថាខ្មែរក្រហម នឹងកាន់កាប់ទីក្រុងភ្នំពេញបន្ទាប់ពីការទម្លាក់គ្រាប់បានបញ្ចប់។

សហព្រះរាជអជ្ញា រាយន័រ បន្តសាកសួរសាក្សីអំពីទំនាក់ទំនងរវាងអ្នកការសែតនៅសម័យ នោះ។ សហព្រះរាជអជ្ញា លើកឡើងពីការបញ្ជាក់របស់សាក្សីថា មានអ្នកការសែតពីក្រុមនៅពេល នោះ គឺអ្នករាយការណ៍ព័ត៌មានជើងចាស់មកពីប្រទេសវៀតណាម និងក្រុមអ្នករាយការណ៍ព័ត៌មានវ័យ ក្មេងជំនាន់ក្រោយ។

លោក ហេដឌ័រមិនបានចុះ«ទៅយកព័ត៌មានដោយផ្ទាល់»ឲ្យដូចនឹងអ្នកសារព័តមាន«ដែលចុះទៅ រាយការណ៍ដោយផ្ទាល់នៅសមរភូមិ»នោះទេ។ ក៏ប៉ុន្តែគាត់ចុះទៅយកការណ៍នៅកន្លែងមួយចំនួនដូចជា នៅខត្តុង និងបាត់ដំបងជាដើម។ សាក្សីបានចំណាយពេលធ្វើការស្រាវជ្រាវនៅបណ្ណាដ្ឋានជាតិ នៅក្នុង ទីក្រុងភ្នំពេញផងដែរ។

សាក្សីរាយការណ៍អំពីព្រឹត្តការណ៍មួយចំនួន ដូចជាបាតុកម្មប្រឆាំងនឹង លន់ នល់ នៅភ្នំពេញ ដែលបណ្ដាលឲ្យរដ្ឋមន្ត្រី លន់ នល់ ពីររូបបាត់បង់ជីវិត និងការវាយប្រយុទ្ធរបស់ខ្មែរក្រហមក្នុងការ កាន់កាប់ក្រុងភ្នំពេញនៅឆ្នាំ១៩៧៥។ របាយការណ៍ចុងក្រោយរបស់សាក្សី និយាយអំពីការជម្លៀស បុគ្គលិកស្ថានទូតអាមេរិកចេញពីប្រទេសកម្ពុជា និងការចូលកាន់កាប់ទីក្រុងភ្នំពេញរបស់ខ្មែរក្រហម។

លោក ហេងឌ័រ រៀបរាប់ថា មុនដំបូងគាត់រស់នៅជាយក្រុងភ្នំពេញ តែក្រោយមកគាត់ក៏ផ្លាស់ប្តូរទីលំនៅដោយសារតែគ្រាប់ផ្លោងខ្មែរក្រហម ។ សហព្រះរាជអជ្ញាស្នើរសុំឲ្យលោក «ពិពណ៌នាពីទិដ្ឋភាព» ទីក្រុងភ្នំពេញនៅពេលនោះ ។ សាក្សីលើកឡើងថាប្រជាជននៅទីក្រុងភ្នំពេញរស់នៅក្នុងសភាពភ័យរន្ធត់ ដោយសារគ្រាប់ផ្លោងខ្មែរក្រហម ហើយគាត់ត្រូវជីករូងលាក់ខ្លួននៅក្រោមផ្ទះរបស់គាត់ ។ អ្នកក្រុងភ្នំពេញអាចមើលឃើញគ្រាប់រ៉ុក្កែតពីមាត់ទោទន្លេ ដែលខ្មែរក្រហមបាញ់ចូលទីក្រុងពីទិសខាងលិច ។ សាក្សីនៅចាំថាបញ្ហាសេដ្ឋកិច្ចនៅក្នុងទីក្រុងភ្នំពេញកាន់តែមានភាពតឹងតែងឡើងៗ ។

នាយកនិពន្ធរបស់ទស្សនាវដ្តី ថាម ស្នើរឲ្យគាត់សរសេរអត្ថបទមួយថា តើប្រជាជននៅក្រុងភ្នំពេញ មានរំពឹងថានឹងមានការសម្លាប់រង្គាលដែរទេ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ។ លោក ហេងឌ័រ រកឃើញថាប្រជាជនរស់នៅក្រុងភ្នំពេញពេលនោះ មិនមានរំពឹងថានឹងមានការសម្លាប់រង្គាលនោះទេ ដោយសារតែអ្នកទាំងអស់គ្នាមានជំនឿលើ ខៀវ សំផន ។

តាមរយៈព័ត៌មានដែលគាត់បានទទួលបានពីបុគ្គលិកយោធាជប៉ុនម្នាក់ កងទ័ពខ្មែរក្រហមនៅភូមិភាគពិសេស ជាក្រុមដែលបាញ់ផ្លោងគ្រាប់កាំភ្លើងចូលក្រុងភ្នំពេញ ហើយកងពលភូមិភាគបូព៌ាមួយ ឬពីរកងពលជាអ្នកផ្លោងគ្រាប់រ៉ុក្កែត ១០៧ មីលីម៉ែត្រចូលក្រុងភ្នំពេញ ។ សាក្សីនៅចាំថា គ្រាប់ផ្លោង និងគ្រាប់រ៉ុក្កែតបានបង្កភាពមហន្តរាយដ៏ធ្ងន់ធ្ងរនៅពេលនោះ ដោយហេតុថាគ្រាប់ផ្លោងភាគច្រើនធ្លាក់លើផ្ទះប្រជាជន ។ គាត់និយាយថា គ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរបំផុតកើតឡើងនៅពេលដែលគ្រាប់ផ្លោងធ្លាក់លើស្ថានីយប្រេងឥន្ធនៈ ។

ពេលនៅភ្នំពេញ សាក្សីទទួលបានព័ត៌មានដែលភ្នាក់ងារសម្ងាត់ស៊ីវិល លន់ នល់ ប្រមូលបានទាក់ទងនឹងរចនាសម្ព័ន្ធយោធាខ្មែរក្រហម និងមេដឹកនាំយោធាសំខាន់ៗមួយចំនួនដូចជា តាម៉ុកជាដើម ។ លើសពីនេះទៅទៀត បុគ្គលិកស្ថានទូតមួយចំនួនមើលឃើញលោក ហេងឌ័ «ជាចៃបណ្ណសារដ្ឋាន» រហូតដល់ធ្វើឲ្យគេមានចិត្តអាណិតដល់គាត់ ។ សាក្សីសន្និដ្ឋានថា គាត់ប្រហែលជាមានឯកសារខ្មែរក្រហមជាងអ្នកស្រាវជ្រាវផ្សេងទៀត បើទោះបីជា គាត់មិនដឹងថាតើអ្នកទាំងនោះមានឯកសារអ្វីខ្លះ ហើយនឹងមិនអាចធ្វើប្រៀបធៀបបានក៏ដោយ ។

ទាក់ទងទៅនឹងព័ត៌មានដែលផ្សាយតាមវិទ្យុ សាក្សីបានស្តាប់សន្ទរកថាមួយចំនួនដែលនិយាយពីគោលដៅបក្សដិវត្តន៍ ។ ហើយជាក់ស្តែង គាត់ក៏បានអានសេខក្តីសង្ខេបព័ត៌មានរបស់របាយការណ៍ភ្នាក់ងារផ្សព្វផ្សាយព័ត៌មានអន្តរជាតិ ។ គាត់ប៉ាន់ប្រមាណថាមានសន្ទរកថារបស់ ខៀវ សំផន ចំនួន១២ ត្រូវបានចាក់ផ្សាយតាមវិទ្យុ ។

ពេលត្រលប់ទៅពិភាក្សាឯកសារទាក់ទងនឹង ប៉ុល ពត និង ខៀវ សំផន សហព្រះរាជអជ្ញារយេន័រ ស្នើរឲ្យសាក្សីធ្វើការបកស្រាយនៅពេលដែល ខៀវ សំផន ធ្វើជាប្រធាននៅសមាជជាតិលោកទីពីរ ។ សាក្សីនៅចាំថា គាត់បានអានព័ត៏មាននេះ នៅក្នុងឯកសារទូរលេខរបស់ស្ថានទូតអាមេរិក ប៉ុន្តែគាត់មិនចាំច្បាស់ថាឯកសារមួយណានោះទេ ។

លោក ហេដឌ័រ ជម្រាបទៅលើតុលាការថាគាត់ទទួលបានភស្តុតាងពីការសម្ភាប់អតីតមន្ត្រីរដ្ឋការលន់ នល់ ១៧រូបពីលោក ដេវីដ ហ៊ិក អតីតនាយាកអង្គការលើកលែងទោសរបស់សហរដ្ឋអាមេរិក ។

ទាក់ទងទៅនឹងតួនាទីរបស់ ខៀវ សំផន សាក្សីជម្រាបតុលាការថា នៅខែខសភាឆ្នាំ១៩៧៥ សមាជ បក្សកុំម្មុយនីសកម្ពុជាបានបង្ហាញពីតួនាទីរបស់ខៀវសំផននៅថ្នាក់មជ្ឈឹម ។ ប៉ុន្តែ ខៀវ សំផន មិនមានតំណែងអ្វីនៅក្នុងគណៈអចិន្ត្រៃយ៍នោះទេ ។ លោក ហេដឌ័រនិយាយថា គាត់បានដឹងមានមនុស្សម្នាក់ទៀត ដូចគ្នានឹង ខៀវ សំផន ដែរ ជាសមាជិកគណៈមជ្ឈឹមបក្ស ហើយតែងតែចូលរួមប្រជុំជាមួយគណៈអចិន្ត្រៃយ៍ ។ មនុស្សម្នាក់នោះឈ្មោះ ឌឿន ។

នៅពេលផ្តល់បទសម្ភាសន៍ជាមួយនឹងលោក ហេដឌ័រ ខៀវ សំផនបានប្រាប់លោក ហេដឌ័រ ថា គាត់ជឿជាក់ថា មានគិញយួនបង្កប់ខ្លួនទាំងនៅក្នុងថ្នាក់មជ្ឈឹមនិងគណៈអចិន្ត្រៃយ៍ ។

ទាក់ទងទៅនឹងការបោះឆ្នោត និងតួនាទីនៅក្នុងនៅសភា លោកហេដឌ័រ បានធ្វើបទសម្ភាសន៍ជាមួយនឹងលោក ម៉ាត់ លី ។ នៅក្នុងបទសម្ភាសន៍នោះ លោក ម៉ាត់ លី បញ្ជាក់ថានៅក្នុងសន្លឹកឆ្នោតទាំងអស់ មានតែឈ្មោះបេក្ខជនម្នាក់គត់ ហើយសមាជិកអាចឆូតឈ្មោះបេក្ខជននោះចោល បើសិនជាគេឈប់គាំទ្របេក្ខជននោះ ។ បទសម្ភាសន៍នេះក៏បានបញ្ជាក់ថា សមាជិកសភាទាំងអស់ទះដៃអប់អរសាទរភ្លាម នៅពេលប្រកាសឈ្មោះសមាជិកគណៈគណៈអចិន្ត្រៃយន៍ ។

កិច្ចប្រជុំសភាមានរយៈពេលពីរម៉ោង ហើយសមាជិកទាំងអស់ដែលចូលរួមត្រូវស្លៀកពាក់ផ្លូវការជាមួយនឹងក្រវ៉ាត់ករ ។ នៅទីបំផុត ការប្រកាសបញ្ចប់ការប្រជុំសភាជាតិត្រូវបានធ្វើឡើង ហើយច្បាប់បញ្ញត្តិទាំងឡាយ និងរដ្ឋមន្ត្រីត្រូវបានអនុម័តនិងប្រកាស់ឡើងជាផ្លូវការ ។

ទាក់ទងទៅនឹងការចេញបញ្ជាឲ្យសម្លាប់មនុស្ស លោក ហេដ័រ បានសរសេរនៅក្នុងសៀវភៅរបស់គាត់ថាគ្រប់ផ្នែកទាំងអស់មានអំណាចផ្សេងៗគ្នាក្នុងការចេញបញ្ជាឲ្យសម្លាប់ ។ លោក ហេដឌ័រ បង្ហាញភស្តុតាងគាំទ្រការលើកឡើងខាងលើនេះ តាមរយៈឯកសារទាក់ទងនឹងសមមិត្ត ឌឿន ដែលអ្នកបេះដឹង ម្នាក់ទទួលបន្ទុកមន្ទីរ៨៧០ ។ មន្ទីរនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាធ្វើយ៉ាងណាឲ្យសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយន៍ត្រូវបានទៅអនុវត្តន៍ ។

ក្រោពីសេចក្ដីសម្រេចនៅមន្ទីស-២១ សាក្សី បានពិនិត្យឯកសារមួយចំនួនដែលបង្ហាញពីតួនាទីរបស់មន្ទីរ៨៧០ ប៉ុន្ដែគាត់មិនចាំឯកសារទាំងអស់នោះទេ។ តាមរយៈឯកសាររបស់ ឌឿន លោក ហេដឌ័រ បានដឹង ថាពីការសម្លាប់សមាជិករដ្ឋាភិបាលរួបរួមជាតិដែលបង្កើតឡើងដោយសម្ដេចសីហនុ នៅទីក្រុងប៉េកាំង ចំនួន១៦នាក់។

សាក្សីលើកឡើងថាមានឯកសារដែលបញ្ជាក់ថា ប៉ុល ពត ធ្វើការកោតសរសើរ ខៀវ សំផន។ គាត់មិនបានចាំច្បាស់ពីអំពីឯកសារផ្សេងទៀតដែលបង្ហាញពីការកោតសរសើររបស់ ប៉ុល ពត ទៅកាន់មេដឹកនាំជាន់ខ្ពស់ផ្សេងទៀត។ សាក្សីដឹងពីឯកសារមួយចំនួនទៀត ដែលបង្ហាញថា ខៀវ សំផន ត្រូវបានតែងតាំងធ្វើជានាយករដ្ឋមន្ត្រី ហើយសាក្សីបានបញ្ជាក់ថាឯកសារទាំងអស់ពិតជាត្រឹមត្រូវ និងអាចទទួលយកបាន។

តាមរយៈបទសម្ភាសន៍របស់លោក ហេដឌ័រ ជាមួយនឹង ខៀវ សំផន ការសម្លាប់កើតឡើងដោយសារតែមានភ្នាក់ងារវៀតណាម ហើយនៅឆ្នាំ ១៩៧៧-១៩៧៨ ភ្នាក់ងារនោះត្រូវបាន«ដកចោល»។ តាមរយៈបទសម្ភាសន៍ថតសម្លេងនេះ នៅពេលដែលសួរថា ប្រជាជនដែលមិនមែនជាភ្នាក់ងារសម្ងាត់នោះត្រូវទទួលការចោទប្រកាន់ថាជាខ្មាំង និងត្រូវយកទៅសម្លាប់ ខៀវ សំផន បានបដិសេធនឹងការលើកឡើងនេះ ដោយបញ្ជាក់ថា “យួន” ជាអ្នកធ្វើឲ្យមានការការចោទប្រកាន់ក្លែងក្លាយនេះ តែខ្មែរក្រហមបានរារាំងសកម្មភាពទាំងនេះ។

តាមរយៈបទសម្ភាសន៍ថតសម្លេងនេះដែរ លោក ហេដ្ឌឺ ចោទសួរ ខៀវ សំផន នូវសំណួរមួយថា តើមានប្រជាជនមួយចំនួនត្រូវបានចោទប្រកាន់ខុស។ ខៀវ សំផត ឆ្លើយតបវិញ ការចោទប្រកាន់បែបនេះមិនដែលកើតមានឡើងទាល់តែសោះ សូម្បីតែម្ដងក៏ដោយ។ ពេលដែលសួរសំនួរទាំងនោះ លោក ហេដ្ឋឌ័រ ដឹងខ្លួនថាលោកកំពុងតែវាយប្រហារលោក ខៀវ សំផន ដែលមិនបានរំពឹងទុកថា និងសំនួរទាំងអស់នេះសោះ។

ដើម្បីបានបទសម្ភាសន៍នេះ លោក ហេដឌ័របញ្ជាក់ថា គាត់ត្រូវធ្វើដំណើរឆ្លងកាត់ព្រំដែនថៃដើម្បីជួប សម្ភាសន៍លោក ខៀវ សំផន បន្ទាប់ពីសន្និព័ត៌មានមួយ។

នៅក្នុងសៀវភៅរបស់គាត់ លោក ហេដ្ឋឌ័រ គាត់បានពិភាក្សាអំពីឯកសារសរសេរដោយលោក ខៀវ សំផន ដែលអះអាងថា ការស្លាប់ភាគច្រើនទាក់ទងជាមួយនឹងសត្រូវ បើទោះបីជាករណីនៅកន្លែង ដែលមានមនុស្សស្លាប់ដោយសារការអត់ឃ្លានក៏ដោយ។ លោក ខៀវ សំផន បានអះអាងថាកម្មករមានជីវភាពធូរធានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។

អង្គជំនុំជម្រះសម្រេចបិទសវនាការ ហើយតុលាការនឹងបន្តស្តាប់សក្ខីកម្មរបស់សាក្សីដដែរនេះ នៅវេលាម៉ោង ៩ព្រឹក ថ្ងៃច័ន្ទ ទី១៥ ឆ្នាំ២០១៣ ។

-ចប់-